# ការសំភាសន៍របស់លោកអ៊ុំ  សុក ស៊ុត

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ  រ៉េន សារិន        ខៈ អ្នកត្រូវគេសំភាសន៍ សុក  ស៊ុត

## <u>ការសង្ខេបរបស់លោកអ៊ុំ  សុក ស៊ុត</u>

ការសង្ខេបពីខ្ញុំនិមលខ្ញុំចាប់អារម្មណ៍ហើយចូលចិត្តប្រវត្តិរបស់គាត់ខ្លាំងព្រោះថាគាត់រស់នៅគ្មានការផ្លាស់ប្តូរទីកន្លែងរស់នៅសោះគឺគាត់នៅភូមិស្រុកកំណើតគាត់រហូតដល់សព្វថ្ងៃទោះបីជាឆ្លងកាត់ជីវិតលំបាកសង្គ្រាមយ៉ាងណាក៏គាត់នៅតែរស់នៅភូមិកំណើតដែរ។

កៈ
អញ្ចឹងអ៊ុំជាដំបូងខ្ញុំសូមអរគុណអ៊ុំដែរបានអោយខ្ញុំសំភាសន៍អំពីប្រវត្តិរបស់អ៊ុំចឹងហ្អាសណាហើយការសំភាសន៍នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យនៅប្រទេសអាមេរិកដែរមានឈ្មោះថា
BYUអញ្ចឹងសកលវិទ្យាល័យមានគោលបំណងមួយចង់រក្សាប្រវត្តិប្រជាជនខ្មែរទុកអោយកូនចៅជំនាន់ក្រោយៗរបស់អ៊ុំគាត់អាចស្គាល់ពីប្រវត្តិដូនតាឬក៏ស្គាល់ពីប្រវត្តិរបស់អ៊ុំអញ្ចឹងហ្អាសណា។ចាសពេលដែរខ្ញុំសំភាសន៍ប្រវត្តិរបស់អ៊ុំខ្ញុំហ្នឹងចូលក្នុងវេបសាយ៍របស់សាលាដែរមានឈ្មោះថា
www.cambodaioralhistrie.byu.eduហើយអញ្ចឹងអ៊ុំតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍របស់អ៊ុំចូលទៅក្នុងវេបសាយ៍របស់សាលាហ្អេសអ៊ុំ?

ខៈ ហ្អឺបើក្មួយសុំដាក់ហើយដាក់ទៅ។

កៈ ចាស។

ខៈ កុំអោយឡើងលេងចៅកុំអោយឡើងទៅលើចៅ។

កៈ ចាសអញ្ចឹងអើរសំរាប់ខ្ញុំនាក់សំភាសន៍អ៊ុំខ្ញុំឈ្មោះថារ៉េន
សារិនហើយថ្ងៃទីដែរខ្ញុំហ្នឹងសំភាសន៍អ៊ុំគឺថ្ងៃទី០៣ខែ០៨ឆ្នាំ២០១៧ហើយទីតាំងនៅភូមិព្រៃស្វាយឃុំរាំងគេស្សីស្រុកសង្កែខេត្តបាត់ដំបងហ្អាសណាអ៊ុំ។អញ្ចឹងខ្ញុំសួរថាអ៊ុំឈ្មោះអីដែរឈ្មោះពេញរបស់អ៊ុំហ្អាស?

ខៈ ឈ្មោះសុក ស៊ុត។

កៈ ចាសហើយអ៊ុំចាំថាអ៊ុំមានដូចជាឈ្មោះហៅក្រៅហ្អេសអ៊ុំ?

ខ៖ អត់មានទេ។

ក៖ តាំងពីតូចអីអត់មានទេណាអ៊ុំណា?

ខ៖ អត់ទេ។

ក៖ ចាសចុះអ៊ុំអើរមានអាយុមាណឆ្នាំហើយឆ្នាំនេះហ្អាស?

ខ៖ ថា៥៩ទៅចូលឆ្នាំថ្ងៃហ្នឹងម៉ាមាណថ្ងៃទៀតចូលឆ្នាំហើយ។

ក៖ អញ្ចឹង៥៩ណាអ៊ុំ?

ខ៖ ៥៩ទៅ។

ក៖ ចាសចុះអ៊ុំដឹងថាអ៊ុំកើតនៅឆ្នាំណាខែណាថ្ងៃណាហ្អេស?

ខ៖ ឆ្នាំដឹងឆ្នាំឆ្នាំកោពិនមិនដឹងខែថ្ងៃមិនដឹងខែបារាំងមិនដឹងមិចមិនដឹងដែរប៉ុនតែឆ្នាំខ្មែរដឹងឆ្នាំកោ។

ក៖ ចាសអញ្ចឹងនៅក្នុងអតសញ្ញាណបទអ៊ុំនៅកើតនៅថ្ងៃទី០២ខែ០៣ឆ្នាំ១៩៥១។

ខ៖ ហ្អឺ!

ក៖ ចាសហ្នឹងក្នុងអតសញ្ញាណបទរបស់អ៊ុំហ្អាស។?

ខ៖ ហ្អឺ!

ក៖ តែឆ្នាំខ្មែរឆ្នាំកោណាអ៊ុំណា?

ខ៖ ឆ្នាំកោ។

ក៖ ត្រូវហ្នឹងសត្វអីគេអ៊ុំ?

ខ៖ ជ្រូក។

ក៖ សត្វជ្រូកចាសចុះអ៊ុំអើស្រុកដូចជាទីកន្លែងកំណើតរបស់អ៊ុំអ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ ព្រៃស្វាយហ្នឹង។

ក៖ ភូមិព្រៃស្វាយ ឃុំរាំងកេស្សី ស្រុកសង្កែ ខេត្តបាត់ដំបងហ្នឹងហ្អេសអ៊ុំ?

ខ៖ ហ្អឺ!។

ក៖ ចាសចុះអឹមអញ្ចឹងអ៊ុំកើតនៅហ្នឹងរស់នៅហ្នឹងមង?

ខ៖ ហ្នឹងនៅហ្នឹងមង។

ក៖ ចាសហើយ?

ខ៖ ដឹងក្តីហ្នឹងបណ្តោយហ្នឹង។

ក៖ ចាសចុះអ៊ុំបងប្អូនអ៊ុំមានចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូនទាំងអស់នៅ៦។

ក៖ ៦នាក់?

ខ៖ អើនៅតែប្រាំទេអស់មួយហើយ។នៅតែប្រាំទេ។

ក៖ អញ្ចឹងទាំងអស់ទាំងស្លាប់ទាំងរស់គឺ៦នាក់?

ខ៖ ប្រាំមួយ។

ក៖ ចាសហើយអ៊ុំជាកូនទីមាណដែរ?

ខ៖ ទីបួន។

ក៖
ជាកូនទីបួន។ចុះអ៊ុំដឹងថាពួកគាត់ឈ្មោះអីគេខ្លះហ្អេសអ៊ុំ?អ៊ុំអាចរៀបរាប់ឈ្មោះពីបងេហូតដល់កូនពៅហ្អាសណាអ៊ុំ?

ខ៖ បងសឿម បងសឿ បងស្រឺន ម៉ីសាម៉យ អាពៅ
អាពៅហ្នឹងអាឈុនលីហ្នឹងសុទ្ធតែឈ្មោះពិតប្រាកដទាំងអស់ងហ្នឹង។

ក៖ ចាសអ៊ុំចាំទាំងអស់។

ខ៖ ហ្អឺ!

ក៖ ចុះអ៊ុំចាំថាអើអ៊ុំចងចាំសាច់រឿងអីគេខ្លះជាមួយហ្នឹងបងប្អូនរបស់អ៊ុំហ្អាស?

ខ៖
ហ្អឺអ៊ុំមិនសូវចាំទេសាច់រឿងផសគេក៏ដោយអ៊ុំបានគ្រូសាររកស៊ីបែកផ្សេងគ្នាគេរកផ្សេងយើងរកផ្សេងហ្អាស។

ក៖
ចាសតែដូចជានៅជាមួយគ្នាជុំបងប្អូនអ៊ុំមានចាំថាអ៊ុំអីខ្លះជាមួយហ្នឹងពួកគាត់?ពេលវេលាសប្បាយ?

ខ៖ មានធ្វើអីធ្វើស្រែហ្នឹងឯងធ្វើស្រែដើឃ្វៀលគោហ្នឹងឯងគ្មានធ្វើអីទេ។

ក៖ ចាសអញ្ចឹងភាគច្រើនអ៊ុំទៅឃ្វៀលគោអីជាមួយហ្នឹងពួកគាត់?

ខ៖ ឃ្វៀលគោអីធ្វើស្រែហ្នឹង។

ក៖ ចាស

ខ៖ ដល់មកជំនាន់អាពតដើស្មើម៉ាភូមិអីន៏។

ក៖
ចាស។ចុះអ៊ុំពេលដែរអ៊ុំនៅក្មេងៗហ្អាសអ៊ុំចូលចិត្តធ្វើអីខ្លះជាមួយហ្នឹងពួកគាត់ហ្អាសជាមួយហ្នឹងបងប្អូនអ៊ុំហ្អាស?

ខ៖ ថាអ៊ុំថាឃ្វៀលគោអ៊ុំមិនចេះដាំបាយហូបផងហ្នឹង។

ក៖ ចាសអត់ដែរធ្លាប់លេងដូចជាល្បែងកំសាន្តជាមួយពួកគាត់ទេណា?

ខ៖ លេងដែរលេងអាដែងនែស្វាដន្ទើមទីលើដើមឈើលេងហឹងប៉ុណ្ណឹង។

ក៖ ស្វាឡើងអីគេអ៊ុំ?

ខ៖ ស្វាដន្ទើមទីលើដើមឈើហ្នឹង។

ក៖ អរចាស។

ខ៖ ហើយលេងពួនលើដើមឈើទៅអាហ្នឹងក្មេងឃ្វៀលគោមានប្រវត្តិតែប៉ុណ្ណឹង។

ក៖ ហិហិហិអត់ធ្លាប់លេងបោះអីគេបោះហឹងបោះអីទេណាអ៊ុំណា?

ខ៖ អត់ទេ។ហ្នឹងអាវៃហឹងវៃកោលហ្នឹងឯង។

ក៖ ចាស។

ខ៖ វែកោលវៃហឹង។

ក៖ ឥឡូវអ៊ុំនៅតែចេះហ្អេស?

ខ៖ ទេមានល្ងង់អី។

ក៖
ហ៊ិហ៊ិហ៊ិចាសអើចុះអ៊ុំអើពេលដែរអ៊ុំដូចជាពួកគាត់ពេលឥឡូវហ្អាសតើពួកគាត់នៅស្រុកអីគេខ្លះហើយភូមិអីគេខ្លះហើយពួកគាត់ប្រកបមុខរបរអីគេអ៊ុំ?

ខ៖ នៅថ្មគោលតែម្នាក់ទេក្រៅពីហ្នឹងសុទ្ធតែនៅព្រៃស្វាយទាំងអស់។

ក៖ ចាសហើយពួកគាត់ប្រកបមុខរបរអីគេ?

ខ៖ ហើយតែស្រែដូចតែគ្នាទាំងអស់ហ្នឹងឯង។

ក៖ ទាំងអស់ណាអ៊ុំ?

ខ៖
ហ្អឺបើថ្មគោលគាត់ដេកពិសាររហើយគាត់ធ្វើអីលែងកើតហើយដូចថាគាត់ដើបានមែនប៉ុន្តែគាត់ពិសារលើកូនហើយគាត់ធ្វើលែងកើតហើយ។

ក៖ អញ្ចឹងមានន័យថាគាត់ចាស់?

ខ៖ គាត់ចាសហើយចូល៧០ហើយ៧១ឬ៧២ហើយ។

ក៖ អរ។

ខ៖ បងបង្អស់នោះ។

ក៖ ចាសចុះអ៊ុំម្តាយរបស់អ៊ុំឈ្មោះអីដែរ?

ខ៖ ឈ្មោះអែម។

ក៖ ត្រកូលគាត់ហ្អរអ៊ុំ?

ខ៖ ឪពុកគាត់ឈ្មោះសន។

ក៖ អញ្ចឹងសនអែម?

ខ៖ ហ្អឺ!

ក៖ ចុះឪពុករបស់ជីគាត់ឈ្មោះអីដែរ?

ខ៖ សុក។

ក៖ ត្រកូលអីគេអ៊ុំ?

ខ៖ ហង្ស។

ក៖
ហង្សសុកចាសចុះគាត់ទាំងពីនាក់មានអាយុមាណហើយបើសិនជាគិតដល់ឥឡូវហ្អាស
ណាអ៊ុំ?

ខ៖ ឥឡូវហ្នឹងកៅជាអហើយ។

ក៖ ឥឡូវហ្នឹងកៅមាណអ៊ុំ?

ខ៖ មើគាត់ស្មើយាយវ៉ាស្មើតាមិញដែរបែបកៅពីកៅមួយដឹងបើមិនកៅមួយកៅពី។

ក៖ ចាសអ៊ុំដឹងអ៊ុំចាំថាគាត់កើតនៅថ្ងៃណាខែណាឆ្នាំណាហ្អេស?

ខ៖ អត់ដឹងទេព្រោះអីឪម៉ែ។

ក៖ ឪម៉ែអត់ដឹងដែរ?

ខ៖ ឪម៉ែអត់ចេះអក្សទាំងអស់។

ក៖ ចាស។

ខ៖ ព្រោះអីបានអត់ចាំឆ្នាំកូនអត់ចាំថ្ងៃខែកូនហ្នឹងហ្អាសចាំតែឆ្នាំហ្នឹងហ្អាស។

ក៖ ចាសចុះអ៊ុំដឹងថាគាត់ពួកគាត់ទាំងអស់គ្នារកើតនៅណាហ្អេសអ៊ុំ?

ខ៖ គាត់កើតនៅព្រៃស្វាយហ្នឹង។

ក៖ កើតនៅព្រៃស្វាយទាំងអស់គ្នារ?

ខ៖ ហ្អឺនៅព្រៃស្វាយទាំងអស់គ្នារហ្នឹងឯង។

ក៖ ចាស។

ខ៖ ដាក់ទឹកដោះគោក្របាមអូននៅលើកន្ទេលនោះថៅ។

ក៖ ចាស។

ខ៖ ហើយដបនោះដបនៅលើកន្ទេលហ្នឹងដែរនោះនោះនោះដបនោះនោះ។

ក៖ ចាសចុះឪពុកអើរបស់អ៊ុំហ្អាសគាត់ធ្វើអីគេសំរាប់ចញ្ចឹមជីវិតអ៊ុំ?

ខ៖ ស្រែរតែមួយមុខហ្នឹងដូចតែគ្នារហ្នឹងនាក់ស្រែសុទ្ធសាតបណ្ដោយ។

ក៖ ចាសហើយគាត់ជាមនុស្សមិចដែរអ៊ុំ?

ខ៖
ហ្អឺគាត់ធម្មតាមិនដែរចេះរឿងដើផឹកស៊ីហ្នឹងគេមិនចេះបណ្ដោយបារីក៏គាត់មិនចេះគាត់ដឹងតែធ្វើរក។

ក៖ ចាស។

ខ៖
ដូចអ៊ុំអញ្ចឹងដែរអ៊ុំក៏មិនចេះផឹកស៊ីអីដែរបានតែរឿងដូចថាហូបបាយហូបចំណីហូបនំអីចឹង។

ក៖ ចាស។

ខ៖
ប៉ុនថាឥឡូវហ្នឹងរាល់ថ្ងៃហ្នឹងទឹកផ្លែឈើមួយថ្ងៃមួយកំប៉ុងមួយថ្ងៃមួយកំប៉ុងដូចគេរាប់ចឹងដែរមិនស្រួលដែរហ្នឹងមិនឃើញទេមានស្រួលអីមើលថៅឡើងនេះឡើងខ្មៅឡើងអីអស់ហើយហ្នឹងមើលថៅវាអស់ងងុយហ្អរ។

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចញ្ចឹមជីវិតអ៊ុំ?

ខ៖ ថាស្រែរហ្នឹងឯងកើតមកដឹងក្ដីឃើញតែស្រែហ្នឹងបណ្ដោយហ្នឹង។

ក៖ ចាសគាត់អត់មានប្រកមមុខរបរអីផ្សេងទេណាអ៊ុំណា?

ខ៖ អត់ទេ។

ក៖ ចុះគាត់ជាមនុស្សមិចដែរអ៊ុំ?

ខ៖
ទេម៉ែឪធម្មតាដូចយើងចឹងគាត់ថាគាត់មិនឡូឡាមិនរករឿងអីមិនអីណាអត់ទេគាត់ដឹងតែខំរកស៊ីចញ្ចឹមកូនប៉ុណ្ណឹង។

កៈ ចាសចុះអ៊ុំដឹងសាច់រឿងអីគេខ្លះអំពីឪពុកម្ដាយរបស់អ៊ុំហ្អាស?

ខៈ
អ៊ូប្រវត្តិហាត់នឿយណាស់នាក់ស្រែសំការហាត់នឿយណាស់បណ្ដោយដូចអ៊ុំចឹងហាត់នឿយដល់ចាស់ប៉ុន្នឹងហើយនៅទើបតែឈប់ច្រូតកន្ទ្រពីឆ្នាំឆ្នាំហ្នឹងតើពេលមានម៉ាស៊ីនហ្នឹង។

កៈ ចាស។

ខៈ
ហ្អឺអ៊ុំអាយុមិនមែនទិចទេអ៊ុំទើបតែហាត់សំរាកពីឆ្នាំហ្នឹងឆ្នាំហ្នឹងដែរតើឥឡូវមានម៉ាស៊ីនច្រូតហើយដាក់ម៉ាស៊ីនទៅ។

កៈ ចាស។

ខៈ បានថាប្រវត្តិអ៊ុំហាត់នឿយណាស់នាក់ស្រែរមិនស្រួលហ្នឹងគេ។

កៈ
ចាសតែដូចអ៊ុំដឹងថាដូចជាប្រវត្តិរបស់ឪពុកម្ដាយអ៊ុំគាត់អ៊ុំមានអនុស្សាវរីយ៍អីគេខ្លះជាមួយពួកគាត់ហ្អាស?

ខៈ
មានអីមានអនុស្សាវរីយ៍រឿងស្រែប៉ុណ្ណឹងឯងភ្ជួឡើងដឹកគោដឹកក្របីទៅស្រែទៅល្ងាចឡើងដេញមកទៅចងទៅចុះគាត់នាក់ស្រែប្រកមមុខរបររកស៊ីចញ្ចឹមកូនប៉ុណ្ណឹងឯង។

កៈ ចាស។

ខៈ មិនដឹងថាអរម៉ូតូទៅណាទៅណីអត់ទេដឹងតែស្រែមួយមុខប៉ុណ្ណឹងឯង។

កៈ
ចាសចុះអើអ៊ុំគាត់មានប្រាប់អ៊ុំពីជីវិតរបស់គាត់កាលពីគាត់នៅក្មេងៗឬក៏ជីវិតគាត់ជួបរឿងអីគាត់ដែរធ្លាប់ប្រាប់អ៊ុំច្រើនហ្អេស?

ខៈ អត់ទេអត់និយាយប្រាប់អីទេបើថាដឹងតែស្រែមួយមុខប៉ុណ្ណឹង។

កៈ ចាសគាត់អត់ដែរធ្លាប់ប្រាប់ពីបទពិសោធន៍គាត់ក្នុងជីវិតអីចឹងអត់ទេណាអ៊ុំណា?

ខៈ អត់ទេ។

កៈ ចាស។

ខ៖ ដឹងតែស្រែអ៊ុចឹងដឹងតែស្រែអ៊ុមិនដែរដើរទៅស៊ីឈ្នួលណាទេនៅតែស្រែ។

ក៖ ចាសចុះអ៊ុអើអ៊ុចងចាំឈ្មោះរបស់ជីដូនជីតារបស់អ៊ុហ្មេស?

ខ៖ អត់ទេអត់ចាំទេ។

ក៖ អត់ចាំទាំងអស់មងណា?

ខ៖ អត់ទេបើត្រឹមឪហើយហ្នឹងជាតាប៉ុណ្ណឹងឯង។

ក៖ ចាសហ្នឹងហើយជីតារបស់អ៊ុហ្អាស?

ខ៖ ជីតាជីតាហ្នឹងតាហុងហុងសុកហ្នឹង។

ក៖ ចាស។

ខ៖ ខាងម្ដាយសនងែមហ្នឹង។

ក៖ ចាស។

ខ៖ ចាំតែប៉ុណ្ណឹង។

ក៖ ចុះចង់និយាយថា(ក្រហឹម)អើលោកតាលោកយាយខាងម្ដាយគាត់ឈ្មោះអីគេដែរអ៊ុ?

ខ៖
យាយឈ្មោះយាយសានទាំងពីយាយខាងឪក៏សានយាយខាងយាយអែមក៏សានដែរប៉ុន្តែត្រកូលប្ដីផ្សេងគ្នារឈ្មោះផ្សេងមួយឈ្មោះហុងមួយឈ្មោះសើម។

ក៖ ចាសខាងម្ដាយឈ្មោះអីខាងឪពុកឈ្មោះអីអ៊ុ?ឪពុកហ្អាសមានន័យថាតារបស់អ៊ុហ្អាស?

ខ៖ តាហង្សសុកហ្នឹង។

ក៖ ចាសហ្នឹងខាងតា?

ខ៖ ខាងខាងឪ។

ក៖ ចាស។

ខ៖ ខាងម្ដាយសើមអែម។

ក៖ ចាសឪពុកម្ដាយរបស់អ៊ុគាត់មានធ្លាប់ប្រាប់រឿងអីពីជីដូនជីតារបស់អ៊ុហ្មេស?ចាស។

ខ៖ ធ្លាប់ដែរ។

ក៖ ធ្លាប់ប្រាប់ថាមិចខ្លះអ៊ុំ?

ខ៖ ឪពុកគាត់នៅកម្ពុជាក្រោមហ្នឹងមកពីកម្ពុជាក្រោម។

ក៖ ចាសអញ្ចឹងពួកគាត់ជានាក់កម្ពុជាក្រោម?

ខ៖ ហ្អឺ!

ក៖ ចុះក្រុមគ្រួសាររបស់អ៊ុំពួកគាត់រស់នៅខេត្តនេះយូនៅអ៊ុំ?

ខ៖ បើថាម្ដាយនោះគាត់កើតកំណើតនៅព្រៃស្វាយម្ដាយនោះ។

ក៖ ចាស។

ខ៖ បើថាតាមគាត់មកពីកម្ពុជាក្រោមទេដូចទាចឹងនិយាយច្បាស់ដូចទាឯងហ្នឹង។

ក៖ ចាស។

ខ៖
បើយាយកើតមិនទាន់ដឹងបែមុខទៅណាផងហ្នឹងទាន់តែតាតាទេអរទាន់យាយមួយទាន់ម្ដាយខាងឪបើម្ដាយខាងម៉ែអត់ទាន់ទេ។

ក៖ ចុះអ៊ុំដូចជារស់នៅខេត្តនេះរយះពេលមាណហើយអ៊ុំ?

ខ៖
ទេតាំងពីអ៊ុំកើតមកដឹងក្ដីមកនៅហ្នឹងតាំងពីកើតម៉ានៅព្រៃស្វាយហ្នឹងបណ្ដោយក៏ហាជាងហើយជិតហុកហើយ។

ក៖ ហាសិបឆ្នាំហើយណាអ៊ុំណា?

ខ៖ ហ្អឺជិតហុកហើយ។

ក៖ ចាសចុះអ៊ុំមានសាច់ញ្ញាតិដែររស់នៅក្រៅប្រទេសហ្អេសអ៊ុំ?ដូចជាបងប្អូនកូនក្មួយឬក៏?

ខ៖ មិនមានទេអត់ទេ។

ក៖ អត់មានទាំងអស់មងណាអ៊ុំ?

ខ៖ អត់។

កៈ ចុះស្វាមីរបស់អ៊ុំគាត់ឈ្មោះអីដែរអ៊ុំ?

ខៈ ឈ្មោះរើន។

កៈ ទាំងត្រកូលរបស់គាត់ហ្អាស?

ខៈ ធីរ៉ើន។

កៈ ហើយអ៊ុំចាំពេលណាដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ហ្អេសអ៊ុំ?

ខៈ អត់ដឹង៧៩។

កៈ ប្រហែលជា៧៩ហ្អេសអ៊ុំ?

ខៈ ហ្នឹងហើយ៧៩ប្រហែលអី៧៩ហ្នឹងតែមិនដឹងខែណាអីថ្ងៃណាអីមិនដឹងទេ។

កៈ
ចាសចុះពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ហ្នឹងឪពុកម្តាយរៀបចំអោយឬក៏រៀបចំដោយខ្លួនឯងចឹងហ្អាសណាអ៊ុំ?

ខៈ ចិត្តឯង។

កៈ ចាសរៀបចំចិត្តឯងចុះមានថ្លៃបណ្តាការហ្អេសអ៊ុំ?

ខៈ អត់ទេចុះដល់កាល៧៩មានបណ្តាការឯណារកតែអង្ករដាក់ឆ្នាំងមិនឃើញផង។

កៈ ចាសអញ្ចឹងនាក់ណាគេរៀបចំអោយដូចជាអើ?

ខៈ ទៅរែកអង្ករពីជុំរុំយកមកសែនយកមកធ្វើទៅមានអង្ករឯណា?

កៈ អរ។

ខៈ កាលម្ហូក៧៩ហ្នឹងបើយើងមិនទៅរែកមានអង្ករឯណាបរបរមានអង្ករឯណាបាយ។

កៈ ៧៩ចឹងមានន័យថាចេញពីសម័យពលពត២ឆ្នាំណាអ៊ុំណា?

ខៈ ហ្អឺចេញពីសម័យពលពតមកនៅឆ្នាំហ្នឹងសែនឆ្នាំហ្នឹង៧៩ហ្នឹងហើយ។

កៈ
ចាស។ចុះអើអ៊ុំអាចប្រាប់ពីពេលដែរអ៊ុំបានជួបអ៊ុំប្រុសដំបូងបានហ្អេសអ៊ុំហេតុអីបានជាអ៊ុំស្រឡាញ់គាត់អីចឹងហ្អាសណា?

ខ៖ អ្ហូអត់និយាយទេអញនិយាយមិនរួចទេ។

ក៖ មិចអៀនហ្អេសអុំ?

ខ៖ និយាយមិនរួចទេ។

ក៖ ថាគាត់មានលក្ខណៈមិចហើយជួបគាត់នៅកន្លែងណាពេលណាអីចឹងអុំចាំហ្អេស?

ខ៖ មកវែកអង្គរជុំរុំហ្នឹង។

ក៖ ចាសគាត់ជាមនុស្សមិចដែរធ្វើអោយអុំអើចូលចិត្ត?

ខ៖ អ្ហូបើសួរអញ្ចឹងអុំចាស់ជំនាស់នេះហើយអុំនិយាយមិនរួចទេ។

ក៖ ហិហិហិហិអៀនហ្អេសអុំ?

ខ៖ និយាយមិនរួចទេបើដូចក្មេងសព្វថ្ងៃនេះគេទៅព្រួសៗអុំទៅមិនរួចទេ។

ក៖ ចាសអត់អាចប្រាប់បន្តិចបានហ្អេសណាអុំណា?

ខ៖ អ្ហូមិនបាច់ទេ។

ក៖
ហិហិហិអញ្ចឹងអុំចេះភាសារខ្មែរឬអើដូចជាចេះអានឬក៏ចេះសរសេរភាសារខ្មែរបានល្អប៉ុណ្ណាដែរអុំ?

ខ៖ អត់ចេះទេ។

ក៖ អត់ទាំងអស់មងណាអុំណា?

ខ៖ ឆ្លើយអត់ចេះបណ្ដោយ។

ក៖ ចាស។

ខ៖ បើគេសរសេរឈ្មោះអីមើលបានអោយសរសេរសរសេរអត់កើតទេ។

ក៖ អរអញ្ចឹងមានន៧យថាអុំអាចមើលបានតែអត់សរសេរបានទេ?

ខ៖
មើលបានឈ្មោះរបស់ឯងបានឈ្មោះឪឈ្មោះប្ដីរបស់ឯងបានឈ្មោះម៉ែឪរបស់ឯងបានតែអោយសរសេរសរសេរអត់កើតទេ។។

កៈ ចាសតែមើលអក្សរអីផ្សេងៗមើលបានហ្អេសអ៊ុំ?

ខៈ បានខ្លះអត់ដូចថាបានតិចណាស់បណ្តោយនិយាយចេះចុះ។

កៈ ចាស។

ខៈ និយាយថាបានតិចបណ្តោយភាគតិចដប់បានពីអីចេះចុះ។

កៈ ចាស។

ខៈ ព្រោះអីអ៊ុំមិនបានចូលសាលារទេ។

កៈ អ៊ុំអត់បានចូលរៀនទេ?

ខៈ អត់រៀននេះថ្នាក់ពីដើមយើងថ្នាក់ទី១១,១២យើងថ្នាក់ទីមួយទីពីនេះ។

កៈ ចុះអ៊ុំបានរៀននៅសាលារណា?

ខៈ រៀនព្រៃស្វាយហ្នឹង។

កៈ ចាសហើយអ៊ុំចេះភាសារអីផ្សេងក្រៅពីភាសារខ្មែរហ្អេស?

ខៈ អរគ្មានទេអត់ទាំងអស់។

កៈ ថៃចិនវៀកណាមអីចេះហ្អេស?

ខៈ ហ្អឺថាមិនបាច់សួរទេតែខ្មែរមិនចេះផងហ្នឹង។

កៈ ហិហិហិចុះអ៊ុំមានមិត្តភក្រ័ស្និតស្នាលដែរអ៊ុំធំធាត់ឡើងមកជាមួយគ្នារហ្អេសអ៊ុំ?

ខៈ
អត់មានតែកាលនៅរៀនតូចដល់ពេលធំឡើងតាមដំនើររៀងៗខ្លួនយើងសម័យអាពតអស់ហើយមានមិត្តភក្រ័អីទៀត។

កៈ ចាសគាត់ឈ្មោះអីដែរអ៊ុំ?

ខៈ កាលនៅរៀនហ្នឹងសុទ្ធតែនៅហ្នឹងភូមិយើងព្រៃស្វាយហ្នឹងគ្នារងងហ្នឹងណា។

កៈ ចាសមិត្តភក្រ័អ៊ុំហ្នឹងគាត់ឈ្មោះអីគេ?

ខៈ អរខ្ចិលហ្អាសរាប់រៀបអីទេគេមានធ្វូធាអស់ហើយនិយាយធ្វើស្អីទេ។

កៈ
ទេខ្ញុំចង់ដឹងថាអ៊ុំមានមិត្តភក្រ័ហើយគាត់មិចដែរហើយមានអនុស្សាវរិយ៍អីគេខ្លះជាមួយគាត់ចឹងហ្អាសណាអ៊ុំ?ឬក៏គាត់នៅនេះអត់ចឹងហ្អាសណា?

ខៈ មិនបាច់សួរទេអ៊ុំមិនឆ្លើយទេ។

កៈ ហិហិចាសចុះអ៊ុំអើធ្វើការនៅវាលធ្លាប់ធ្វើការនៅវាលស្រែរហ្អេសអ៊ុំ?

ខៈ
ហ្អឺវាលស្រែហ្នឹងទៅមើលគេស្ទូងទៅដកទៅច្រូតហ្នឹងទៅមែនហ្នឹងទៅកាប់ភ្លឺស្រែរកាស់អីហ្នឹងបើថាក្រៅពីហ្នឹងអត់បើសួរអីទៀតអ៊ុំងត់ចេះទេអ៊ុំមានមុខការតែប៉ុណ្ណឹងងំឯង។

កៈ ចាសចុះអ៊ុំធ្លាប់ធ្វើអាជីវកម្មឬក៏ធ្លាប់លក់ដូរអីហ្អេសអ៊ុំ?

ខៈ ទេបើ៧៩រែកស្រារដើលក់មែនកាល៧៩។

កៈ ចាស។

ខៈ
ដំរួចពីហ្នឹងមកឈប់ធ្វើស្រារប្រហែលជាម្ភៃឆ្នាំដែរហើយអាដែងឈប់ដើរឈប់រកស៊ីអីទៅធ្វើតែស្រែនាំកូនធ្វើស្រែរទៅ។

កៈ ចាសអញ្ចឹងធ្លាប់លក់ឌុរដែរណាអ៊ុំណា?

ខៈ ហ្នឹងធ្លាប់រែកស្រារដើរលក់។

កៈ ចាសចុះអ៊ុំធ្លាប់ធ្វើការអីគេខ្លះទៀតនៅក្នុងជីវិតរបស់អ៊ុំហ្អាសហើយ?

ខៈ អត់មានធ្វើការអីទេ។

កៈ ចាស។

ខៈ មានតែស្រែរហ្នឹងហើយនឹងកាប់អុសដុតដាំបាយហូបប៉ុណ្ណឹងឯងមានអីទេ។

កៈ
ចាសចុះអ៊ុំតាំងពីវ៉យក្មេងរហូតមកដល់ពេលនេះហ្អាសអ៊ុំឃើញថាជីវិតរបស់អ៊ុំផ្លាស់ប្តូអ្វីខ្លះអ៊ុំ?

ខៈ ផ្លាស់ប្តូៗយើងចាស់ហ្នឹងឯង។

ក៖ ចាស។

ខ៖ ដូចថាយើងវាមានបាយហូបគ្រប់គ្រាន់មិនពិបាកអីវេងឆ្ងាយ។

ក៖ ចាសចុះអ៊ុំចូលចិត្តពិសារម្ហូបអីដែរអ៊ុំ?

ខ៖ ហ្អឺអ៊ុំតាមបានទេហូបអីក៏អ៊ុំហូបដែរអ៊ុំតាមបានទេ។

ក៖
ចាសចុះអ៊ុំធ្លាប់ចូលចិត្តលេងល្បែងកំសាន្តអីគេខ្លះទៅល្បែងប្រជាប្រិយ៍ចឹងហ្អាសណាអ៊ុំ?

ខ៖
ហ្អឺបើកាលនៅក្មេងចូលឆ្នាអីហ្នឹងវត្តទៅអើតទៅលេងហ្នឹងគេសើចខ្លះដំចាស់អ៊ុំឈប់ហើយ
ឈប់ច្រើនប្រហែលជា១០ឆ្នាំនេះអ៊ុំលេងលេងទៅអើតទៅវត្តទៅសូត្រមន្តសូត្រអីអ៊ុំទៅបើ
ថាទៅលេងអីអ៊ុំលេងទៅហើយនៅតែផ្ទះទេយប់មានទៅណាទេ។

ក៖ ចាសអត់ទៅមើលគេឬក៏អីតេណាអ៊ុំណា?

ខ៖ អត់ថ្ងៃក៏មិនទៅដែរខ្ជិល។

ក៖ ចាសអ៊ុំចូលចិត្តមើលល្បែងប្រជាប្រិយ៍អីគេខ្លះអ៊ុំ?

ខ៖ មើលអាគេវៃឆ្នាំងវៃអីហ្នឹង។

ក៖ មើលអាគេវៃក្អមវៃងីចឹងណាអ៊ុំណា?

ខ៖ អើវៃក្អមហ្នឹង។

ក៖ ចុះលោតបាវអីហ្អេរ?

ខ៖ លោតបាវហ្អេរ?

ក៖ ចាស។

ខ៖ កំរបានទៅមើលណាស់បើថាឮស្ងូគេថាវៃក្អមទៅអើតហ្អាសទៅមើល។

ក៖ អញ្ចឹងអ៊ុំចូលចិត្តមើលគេវៃក្អម?

ខ៖ ហ្អឺ!

កៈ
អរចុះអ៊ុំមានចងចាំបទសម្រៀងណាដែរអ៊ុំធ្លាប់រៀនមកពីតូចហ្អេស?ហើយនៅតែចាំដល់ឥឡូវហ្អាសណា?

ខៈ អ្វូមិនបាច់សួរទេអ៊ុំភ្លេចចង់អស់ហើយ។

កៈ តែអ៊ុំចូលចិត្តស្ដាប់សម្រៀងអត់?

ខៈ
អ៊ុំសព្វថ្ងៃនេះអ៊ុំរ៉ាតយូអ៊ុំឯងនៅឯណោះអ៊ុំដេកឯនេះអ៊ុំឯងស្ដាប់ឯណោះទៅអ៊ុំដេកឯនេះទៅមើលទូរទស្សទៅខ្ជិល។

កៈ ចូលចិត្តអ៊ុំចូលចិត្តមើលទូរទស្សច្រើនជាងស្ដាប់សម្រៀង?

ខៈ ហ្អឺប៉ុន្តែប្រហែលមិនស្រួលហ្នឹងអ៊ុំប្រហែលមួយខែហ្នឹងមិនបានមើលទេ។

កៈ ចាស។

ខៈ
ដឹងតែព្លប់ដេកថ្ងៃបិទណាមកបើកៗទៅដេកទៀតត្រូវមិនស្រួលហ្នឹងអត់ចង់មើលអីទេខ្ជិលហ្អាសគិតតែរឿងដេកទេ។

កៈ ហាត់ណាស់មែនហ្អេសអ៊ុំ?

ខៈ អើមើលមើលថៅទៅវាហាត់ពេក។

កៈ
ចាសចុះអ៊ុំមាននាក់ណានៅក្នុងក្រុមគ្រួសាររបស់អ៊ុំគាត់ចេះលេងឧបករណ៍តន្ត្រីអីហ្អេសអ៊ុំ?

ខៈ អត់។

កៈ
ចាសហើយចុះផ្ទះរបស់អ៊ុំមានលក្ខណៈមិចដែរអ៊ុំតាំងពីក្មេងរហូតដល់ឥឡូវនេះចឹងហ្អាសណា?

ខៈ ហ្អឺកូនឯងមើលឃើញផ្ទះហើយមើល។

កៈ ចាសជាផ្ទះឈើឬក៏ជាផ្ទះអីចឹងហ្អាសណា?

ខៈ ផ្ទះយើងធម្មតាហ្នឹង។

ក៖ ចាស។

ខ៖
អាខ្ពស់មិនថាខ្ពស់ទាបមិនថាទាបកណ្តាលហ្នឹងជញ្ជាំងសាំងអាស្បីក្តារអីហ្នឹងកូនឯងឃើញស្រាប់ហើយតើ។

ក៖
ចាសចុះអើនាក់ណាបានសាងសង់ឬក៏ជួយធ្វើផ្ទះអោយអ៊ុំហ្អេស?ដូចជាមាននាក់ដើម្បីជួយឬក៏អ៊ុំធ្វើដោយខ្លួនឯងចឹងហ្អាសណា?

ខ៖ ផ្ទះទិញគេហ្នឹង។

ក៖
ចាសអញ្ចឹងមានន័យថាអើទិញគេមកហើយយើងគ្រាន់តែជួសជុលខ្លះៗចឹងហ្អេសណាអ៊ុំណា?

ខ៖ ទិញមកជញ្ជាំងអីលើយើងទាំងអស់ទៅ។

ក៖
ចាសចុះអ៊ុំបានជួយសាងសង់សំរាប់ធ្វើផ្ទះមួយហ្នឹងហ្អេស?ដូចជាជួយហុចនេះហុចនោះឬក៏ធ្វើអីចឹងហ្អាសណាអ៊ុំ?

ខ៖ ជួយដូចថាហុចដែកកូលហុចពូថៅអោយគេវៃជំជញ្ជាំងជំអីចឹងទៅ។

ក៖ ចុះអើនាក់ដូចជាសមាជិកនៅក្នុងក្រុមគ្រួសារអ៊ុំគាត់ចេះសាងសង់ផ្ទះអីហ្អេស?

ខ៖ ហ្អឺចុះនេះតចេះចេះវីនអ៊ុំឯងតើអានោះវិន។

ក៖ គាត់ចេះពីនាក់ណាអ៊ុំ?

ខ៖ ចេះពីទារបស់គេទាគេបង្រៀន។

ក៖ ទាតាហ្អា?

ខ៖ ហ្អឺតាបង្រៀន។

ក៖
ចាសចុះអ៊ុំមានជំនាញអីដែរអ៊ុំចេះពីគ្រួសារដូចជាវិញវល្លផ្តៅដូចជាជំនាញកូស្ករអីចេះហ្អេសអ៊ុំ?

ខ៖ អត់។

ក៖
អត់ចេះទេណាអ៊ុ?ចុះអ៊ុអាចប្រាប់ខ្ញុំអំពីជីវិតរបស់អ៊ុពេលដែរអ៊ុពិបាកពេលអីចឹងបានហ្អេសអ៊ុ?

ខ៖ ហ្អឺអរគុណហើយបានហើយប៉ុណ្ណឹងហើយអ៊ុឆ្លើយមិចទៀតទេ។

ក៖ ចាសអញ្ចឹងក្នុងជីវិតរបស់អ៊ុអ៊ុអត់អត់ដឹងថាកាលលំបាកពេលណាទេណាអ៊ុណា?

ខ៖
ហ្អឺមើលមិនឃើញទេសព្វថ្ងៃនេះម្យមហើយបើថាយូតិចទៀតទៅលំបាកមិចមិនថាទេអានេះអ៊ុមិនហានថាទេគឺតិចទៀតទៅវាស្រណុកក៏មិនដឹងអាហ្នឹងអ៊ុមិនហានថាទេ។

ក៖ ចាសកាលពីតូចមកអ៊ុពិបាកអីគេខ្លះចឹងហ្អាសណាអ៊ុ?

ខ៖ អើយហាត់នឿយណាស់រឿងស្រែរឿងភ្លឺហ្នឹង។

ក៖ ចាស។

ខ៖
ធ្វើមិចយើងមានកូនហើយហាត់នឿយចឹងឯងទំរាំកូនបានធំៗអស់តែប៉ុណ្ណឹងបានហើយទៅសំភាសន៏ប៉ុណ្ណឹងហើយទៅ។

ក៖
ចាសមួយទៀតអ៊ុចុះអើបទពិសោធន៏ពេលណាដែរជីវិតរបស់អ៊ុសប្បាយចឹងហ្អាសណាអ៊ុ?

ខ៖ ដូចមិនទាន់មានជីវិតសប្បាយទេនៅ។

ក៖
ចាសហើយចុះអ៊ុអើពីក្មេងរហូតដល់ឥឡូវអ៊ុមានគោលបំណងមួយថាអ៊ុចង់ធ្វើអីដូចជាចង់ធ្វើគ្រូពេទ្យគ្រូបង្រៀនឬក៏អីចឹងហ្វាសណា?

ខ៖
សព្វថ្ងៃនេះអ៊ុចង់តែចូលវត្តទេថ្ងៃសីលអ៊ុចង់តែទៅវត្តទេសព្វថ្ងៃនេះអ៊ុដឹងខ្លួនចាស់ហើយ។

ក៖ ចាស។

ខ៖ អ៊ុនិយាយត្រង់រឿងសប្បាយដើរសប្បាយដើរអីអ៊ុអត់ចង់ទេ។

ក៖ ចាស។

ខ៖ ចឹងបានមីអូនមកហ្នឹងរឿងណាធ្វើបុណ្យអ៊ុំទៅណាប្រាប់បុណ្យអ៊ុំទៅ។

ក៖ ចាស។

ខ៖
អ៊ុំគិតអញ្ចឹងដែរព្រោះអ៊ុំចាស់ហើយអ៊ុំមិនគិតថាអរដើរទៅលេងសប្បាយអរអីហ្នឹងគេអត់ទេ
អ៊ុំគិតចឹងឯង។

ក៖
ចាសចុះអ៊ុំបើសិនជាអ៊ុំអាចប្រាប់អ្វីមួយអោយទៅកូនចៅជំនាន់ក្រោយៗហ្អាសតើអ៊ុំហ្នឹងប្រាប់អ្វីខ្លះទៅកាន់ពួកគាត់ដូចជាជូនពរអីគេខ្លះទៅកាន់គាត់ហើយផ្តាំផ្ញើថាអោយគាត់ក្លាយជាក្មេងបែបណាចឹងហ្អាសណាអ៊ុំ?

ខ៖
អ៊ុំចង់បានអោយតែកូនល្អរកូនមួយណាក៏ដោយអត់មានចង់បានអីអោយតែកូនល្អរដែរតើអ៊ុំមិនចង់ថា
អូដើរពាលាពៃលែអីអ៊ុំអត់ចង់បានទេចង់បានអោយកូនស្គាល់ម្តាយស្គាល់ឪពុកចង់អោយកូនដើរទៅណាអោយកូនល្អរគិតតែប៉ុណ្ណឹងឯង។

ក៖ ចាស។

ខ៖
ហើយសព្វថ្ងៃហ្នឹងអ៊ុំធ្វើបុណ្យគិតតែប៉ុណ្ណឹងឯង។បុណ្យអុចធូបបុណ្យអីចឹងឯងបុណ្យអោយតែកូនល្អរទេ។

ក៖ ហើយអ៊ុំមានអីទៀតចង់ផ្តាំផ្ញើទៅកាន់ពួកគាត់ទៀតហ្អេសអ៊ុំ?

ខ៖ អត់មានអីទៀតទេអ៊ុំផ្តាំផ្ញើរឿងកូនតែប៉ុណ្ណឹងឯង។

ក៖
ចាសអញ្ចឹងអរគុណច្រើនអ៊ុំសំរាប់ការពិភាក្សារហើយអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំចឹងហ្អាសណាអ៊ុំចាស។